Disability Rights California

*ប្រព័ន្ធការពារ និងការតស៊ូមតិ រដ្ឋកាលីហ្វ័រនីញ៉ា*

# សន្លឹកការពិតអំពីការប្រព្រឹត្តិរើសអើង ៖ មធ្យោបាយធ្វើដំណើរសាធារណ:

***ខែកញ្ញា ឆ្នាំ2019 ឯកសារបោះពុម្ពផ្សាយលេខ 7144.06***

Title II នៃច្បាប់ប្រជាជនសហរដ្ឋអាមេរិកដែលមានពិការភាព (ADA, Americans with Disabilities Act) ហាមឃាត់មិនឲ្យមានការប្រព្រឹត្តិរើសអើង ដោយសារពិការភាព ពីសេវាកម្មមធ្យោបាយធ្វើដំណើរសាធារណ: ។ សេវាកម្មមធ្យោបាយធ្វើដំណើរសាធារណ: មានរួមបញ្ចូលនូវប្រព័ន្ធធ្វើដំណើរតាមផ្លូវកំណត់ ដូចជា រថយន្តក្រុង និងរថភ្លើងអគ្គិសនី ។ ទីភ្នាក់ងារផ្តល់សេវាកម្មមធ្យោបាយធ្វើដំណើរសាធារណ: មិនអាចបដិសេធផ្តល់សេវាកម្មដល់ជនដែលមានពិការភាពជាប់ខ្លួនឡើយ ហើយត្រូវផ្តល់ការសម្រួលសមរម្យ ដល់ពួកគេផងដែរ (ក៏ហៅផងដែរថាជា "ការកែសម្រួលសមរម្យ") ដែលពួកគេត្រូវការ ដើម្បីប្រើប្រាស់សេវាកម្មនេះ ។

## ច្បាប់ ADA Title II – សេវាកម្មមធ្យោបាយធ្វើដំណើរសាធារណ:

នាយកដ្ឋានដឹកជញ្ជូន (Department of Transportation) ធ្វើនិយត្តកម្មចំពោះបទបញ្ញត្តិ ADA ដែលត្រូវអនុវត្តចំពោះសេវាកម្មដឹកជញ្ជូន ។ ខាងក្រោមគឺជាការរាយមុខនៃសេវាកម្មដឹកជញ្ជូនមួយចំនួន តែមិនទាំងអស់ទេ ដែលតម្រូវឲ្យទីភ្នាក់ងារដឹកជញ្ជូនសាធារណ: ត្រូវធ្វើតាមច្បាប់ ADA ។ សូមចូលទស្សនាទំព័រវិបសៃត៍របស់រដ្ឋបាលដឹកជញ្ជូនសហព័ន្ធ អំពីច្បាប់ ADA ដើម្បីអានព័ត៌មានបន្ថែម ៖ https://www.transit.dot.gov/regulations-and-guidance/civil-rights-ada/americans-disabilities-act

## ភាពតម្រូវចំពោះរថយន្តក្រុង និងរថយន្តវែន សម្រាប់ការធ្វើដំណើរតាមប្រព័ន្ធផ្លូវកំណត់ ៖

### ឈប់ធ្វើការប្រកាស ៖

- ក្រុមហ៊ុនរថយន្តក្រុង ត្រូវប្រកាសពីកន្លែងត្រូវដូររថយន្ត កន្លែងផ្លូវបំបែកសំខាន់ៗ ទិសដៅរថយន្ត និងចំណុចផ្សេងៗទៀត

ដើម្បីឲ្យជនមានពិការភាពភ្នែក និងជនមានពិការភាពផ្សេងៗទៀត អាចដឹងបានថាខ្លួនកំពុងធ្វើដំណើរដល់ណាហើយ ។

- ក្រុមហ៊ុនរថយន្តក្រុង ត្រូវប្រកាសអំពីការសំចត នៅពេលដែលមានការស្នើសុំពីអ្នកជិះដែលមានពិការភាពជាប់ខ្លួន ។

ព័ត៌មានអំពីទិសដៅនៅលើរថយន្ត ៖

- រថយន្ត ត្រូវមានព័ត៌មានអំពីទិសដៅ និងផ្លូវរថយន្តបើកបរ នៅពីមុខ និងត្រង់ចំហៀងកន្លែងឡើងចុះ ។ ចំណុចនេះ គឺមានសារៈសំខាន់ជាពិសេស នៅពេលដែលរថយន្ត រត់តាមផ្លូវផ្សេងទៀត ឈប់ត្រង់ចំណតជាមួយគ្នា ។
- ព័ត៌មានអំពីទិសដៅ និងផ្លូវរថយន្ត ត្រូវប្រកាស ដើម្បីធានាបានថា អ្នកដំណើរដែលមានពិការភាពភ្នែក និងពិការភាពដទៃទៀត អាចដឹងបានថា តើខ្លួនត្រូវជិះរថយន្តមួយណា ។

ការលើក និងជម្រាលឡើងរថយន្ត ៖

- រថយន្តទាំងអស់ ត្រូវមានឧបករណ៍ ដូចជាជម្រាល ឬឧបករណ៍សម្រាប់លើកមនុស្សដាក់រថយន្ត ដើម្បីអនុញ្ញាតឲ្យអ្នកដំណើរដែលប្រើរទេះរុញអាចឡើងរថយន្តបាន ។ ឧបករណ៍សម្រាប់លើក ត្រូវមានកម្លាំងអាចលើកទម្ងន់បាន 600 ផោន ហើយត្រូវតែអាចលើករទេះរុញដែលមានទំហំ 30 គុណនឹង 48 អ៊ីញ ។
- ចំពោះអ្នកដំណើរ ដែលប្រើរទេះរុញ ឧបករណ៍សម្រាប់ជំនួយការដើរ ឈើច្រត់ដៃ ឈើច្រត់ក្លៀក ឃ្នាបគាបជើង ឬអ្នកដំណើរដែលមិនអាចឡើងរថយន្តតាមជណ្តើរ ត្រូវអនុញ្ញាតឲ្យពួកគាត់ប្រើឧបករណ៍សម្រាប់លើកដាក់រថយន្ត

ប្រអប់បង់ប្រាក់ថ្លៃធ្វើដំណើរ ៖

- ប្រអប់បង់ប្រាក់ថ្លៃធ្វើដំណើរ ត្រូវមានដាក់តាំងតាមរថយន្ត ដើម្បីកុំឲ្យមានការបង្អាក់អ្នកដំណើរក្នុងការឡើងរថយន្ត

បង្កាន់ដៃ ៖

- បង្កាន់ដៃនៅលើរថយន្ត ត្រូវអាចឲ្យអ្នកនៅខាងក្រៅចាប់បាន ពេលឈានជើងឡើងរថយន្ត។ បង្កាន់ដៃនេះ ត្រូវអាចឲ្យអ្នកដំណើរកាន់បាន គឺចាប់តាំងពីចាប់ផ្តើមឡើង រហូតដល់ជិះក្នុងរថយន្ត គឺរួមបញ្ចូលទាំងពេលដែលអ្នកដំណើរ យកប្រាក់ថ្លៃធ្វើដំណើរមកដាក់ក្នុងប្រអប់បង់ប្រាក់ ។

ស្នើសុំឲ្យឈប់ ៖

- ខ្សែសម្រាប់ទាញ ឬប៊ូតុងសម្រាប់ចុច ត្រូវអាចឲ្យអ្នកដំណើរអង្គុយលើរទេះរុញឈោងដល់ ហើយមិនត្រូវឲ្យមានការ "ពិបាកលូកដល់ ពិបាកលូកម្រាមចូល ឬពិបាកបត់កដៃឡើយ" ។

សត្វផ្តល់សេវាកម្ម ៖

- មនុស្សមានពិការភាពជាប់ខ្លួន មានសិទ្ធិយកសត្វផ្តល់សេវាកម្មតាម តែមិនអាចយកសត្វសម្រាប់ជួយសម្រួលអារម្មណ៍តាមទេ នៅពេលធ្វើដំណើរតាមមធ្យោបាយសាធារណៈ ។ សត្វផ្តល់សេវាកម្ម គឺឆ្កែដែលបានបង្ហឹកសម្រាប់ឲ្យបំពេញកិច្ចការ ឬការងារពាក់ព័ន្ធនឹងពិការភាព សម្រាប់ជួយមនុស្សដែលមានពិការភាពជាប់ខ្លួន ។

## ភាពតម្រូវសម្រាប់ប្រព័ន្ធរថភ្លើងល្បឿនលឿន

- រថភ្លើងល្បឿនលឿន នីមួយៗ យ៉ាងហោចណាស់ ត្រូវមានរថយន្តមួយដែលត្រៀមរួចរាល់ សម្រាប់ឲ្យអ្នកដំណើរមានពិការភាពជាប់ខ្លួនប្រើ ដែលបូករួមទាំងអ្នកដំណើរជិះរទេះរុញ ផងដែរ ។
- ត្រូវមានបង្កាន់ដៃ សម្រាប់ជួយអ្នកដំណើរក្នុងការឡើង និងចុះពីរថភ្លើង ធ្វើចលនាក្នុងពេលនៅក្នុងរថយន្ត ព្រមទាំងពេលត្រូវអង្គុយ និងឈរផងដែរ ។

## ការស្នើសុំការសម្រួលសមរម្យ ពីទីភ្នាក់ងារដឹកជញ្ជូនសាធារណៈ

អង្គភាពដឹកជញ្ជូនសាធារណៈ នីមួយៗ ត្រូវមានដំណើរការសម្រាប់អ្នកដំណើរដែលមានពិការភាពជាប់ខ្លួន ស្នើសុំការសម្រួលសមរម្យចំពោះគោលនយោបាយ និងការអនុវត្តរបស់ខ្លួន ដើម្បីឲ្យពួកគេអាចប្រើប្រាស់សេវាកម្មរបស់ខ្លួន បានដូចគ្នានឹងអ្នកដំណើរដែលមិនមានពិការភាពជាប់ខ្លួន ។ ដំណើរការស្នើសុំការកែសម្រួល ត្រូវតែរៀបរាប់តាមរយៈវិធីសាស្ត្រតែមួយ ដែលក្រុមហ៊ុនដឹកជញ្ជូនប្រើ សម្រាប់ផ្សាយពី ការអនុវត្ត និងគោលនយោបាយរបស់ខ្លួន ទៅកាន់សាធារណៈជនទូទៅ ។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូន ប្រើវ៉ិបសៃត៍របស់ខ្លួន សម្រាប់ផ្សាយពីគោលនយោបាយ និងការអនុវត្តរបស់ខ្លួន នោះដំណើរការសម្រាប់ស្នើសុំការសម្រួល ក៏ត្រូវមានបង្ហោះនៅក្នុងវ៉ិបសៃត៍នោះផងដែរ ។ លើសពីនេះ ដំណើរការស្នើសុំការសម្រួល ត្រូវតែអាចឲ្យអ្នកដំណើរដែលមានពិការភាពជាប់ខ្លួនអាចចូលប្រើបាន ។

តាមដែលអាចធ្វើបាន ជាការប្រសើរបើអ្នកស្នើសុំការសម្រួលសមហេតុផលទុកជាមុន ដោយការប្រើគំរូលិខិតស្នើសុំ និងលិខិតគាំទ្រ ដែលមាននៅខាងចុងនៃសន្លឹកការពិតនេះ ។ បើអ្នកមិនអាចធ្វើការស្នើសុំការសម្រួលសមរម្យ ទុកជាមុនទេ គឺអ្នកអាចស្នើសុំក្រុមហ៊ុនរថយន្តក្រុង ឲ្យផ្តល់ការសម្រួលដែលអ្នកត្រូវការ ។

ពាក្យស្នើសុំការសម្រួលសមរម្យ ដែលធ្វើឡើងដោយជនមានពិការភាពផ្ទាល់ខ្លួន អាចបដិសេធបាន ចំពោះតែមូលហេតុ ដូចខាងក្រោម ៖

- ការស្នើសុំនោះ មិនចាំបាច់ ដើម្បីអនុញ្ញាតឲ្យអ្នកដំណើររូបនោះ អាចប្រើប្រាស់មធ្យោបាយប្រព័ន្ធធ្វើដំណើរសាធារណៈ
- ការផ្តល់ជូនតាមការស្នើសុំ អាចនាំឲ្យមានការកែប្រែជាមូលដ្ឋាននូវស្ថានភាពនៃសេវាកម្ម កម្មវិធី ឬសកម្មភាពការងារ ឬ
- ការផ្តល់ជូនការស្នើសុំ អាចបង្កឲ្យមានការគម្រាមកំហែង ដល់សុខភាព ឬសុវត្ថិភាព អ្នកដទៃ ។

**ដំណើរការដាក់ពាក្យប្ដឹង ចំពោះទីភ្នាក់ងារដឹកជញ្ជូនសាធារណៈ ៖**

ការិយាល័យទីភ្នាក់ងារដឹកជញ្ជូនសាធារណៈ (FTA, Federal Transit
Administration) ផ្នែកសិទ្ធិពលរដ្ឋ គឺជាទីភ្នាក់ងារ ដែលទទួលពាក្យបណ្ដឹង
ស្ដីអំពីការប្រព្រឹត្តិរំលោភចំពោះច្បាប់ ADA សម្រាប់ទីភ្នាក់ងារដឹកជញ្ជូនសាធារណៈ
ប្រចាំមូលដ្ឋាន ។ បើអ្នកជឿថា មានការប្រព្រឹត្តិរំលោភច្បាប់ ADA បានកើតឡើង
ការិយាល័យ FTA ផ្នែកសិទ្ធិពលរដ្ឋ ណែនាំឲ្យអ្នកដាក់ពាក្យប្ដឹងដោយផ្ទាល់ទៅកាន់
ទីភ្នាក់ងារដឹកជញ្ជូនសាធារណៈប្រចាំមូលដ្ឋាន ដើម្បីផ្ដល់ឱកាស
ឲ្យទីភ្នាក់ងារនោះអាចកែតម្រូវ ឬឆ្លើយតបចំពោះក្ដីកង្វល់របស់អ្នក មុនពេលអ្នក
សម្រេចចិត្តដាក់ពាក្យប្ដឹងទៅកាន់ FTA ។

នាយកដ្ឋានដឹកជញ្ជូន (DOT, Department of Transportation) តម្រូវឲ្យ
ទីភ្នាក់ងារដឹកជញ្ជូននីមួយៗ ប្រចាំមូលដ្ឋាន មានដំណើរការសម្រាប់ការប្ដឹងផ្ដល់ ។
អ្នកអាចស្វែងរកដំណើរការបណ្ដឹង របស់ទីភ្នាក់ងារដឹកជញ្ជូនប្រចាំមូលដ្ឋានបាន
ដោយការទាក់ទងពួកគេ ដោយផ្ទាល់ ឬក៏ដោយការ
ចូលទៅកាន់វិបសៃត៍របស់ពួកគេ បើមាន ។

បើទីភ្នាក់ងារដឹកជញ្ជូនប្រចាំមូលដ្ឋាន មិនឆ្លើយតបចំពោះកង្វល់របស់អ្នក
គឺអ្នកអាចសម្រេចចិត្ត ដាក់ពាក្យប្ដឹងមកកាន់ការិយាល័យ FTA ផ្នែកសិទ្ធិពលរដ្ឋ
ដោយការបំពេញសំណុំបែបបទ រួចផ្ញើវាតាមប្រៃសនីយ ទៅកាន់ ៖

អ្នកអាចទទួលបានសំណុំបែបបទពាក្យបណ្ដឹង ពីតំណនេះ ៖
https://www.transit.dot.gov/sites/fta.dot.gov/files/docs/Consolidated_Civil_Rights_Complaint_Form.pdf

ក្រៅពីសំណុំបែបបទ ពាក្យប្ដឹងដែលអ្នកផ្ញើមកយើងខ្ញុំ ត្រូវមានរួមបញ្ចូលចំណុច
ដូចខាងក្រោម ៖

- សេចក្ដីសង្ខេបអំពីបទចោទប្រកាន់របស់អ្នក
  បូករួមទាំងឯកសារគាំទ្រនានា
- ព័ត៌មានលំអិតគ្រប់គ្រាន់ សម្រាប់អ្នកស៊ើបអង្កេត
  អាចយល់បានពីមូលហេតុដែលអ្នកជឿថា ក្រុមហ៊ុនផ្ដល់សេវាកម្មសាធារណៈ
  បានប្រព្រឹត្តរំលោភសិទ្ធិរបស់អ្នក ដោយត្រូវមានរៀបរាប់
  លំអិតអំពីកាលបរិច្ឆេទ និងពេលវេលា នៃហេតុការណ៍ដែលបានកើតឡើង ។
- ការឆ្លើយឆ្លងដែលជាប់ពាក់ព័ន្ធនានារបស់ក្រុមហ៊ុនផ្ដល់សេវាកម្មដឹកជញ្ជូន
  ។

ផ្ញើតាមប្រៃសនីយនូវសំណុំបែបបទដែលអ្នកបានបំពេញព័ត៌មានរួចរាល់
និងឯកសារភ្ជាប់នានាទៅកាន់អាសយដ្ឋានខាងក្រោម ៖

Federal Transit Administration
Office of Civil Rights
Attention: Complaint Team

East Building, 5th Floor – TCR
1200 New Jersey Avenue, SE
Washington, DC 20590

- អ្នកត្រូវដាក់ពាក្យប្តឹង FTA ឲ្យបានក្នុងរវាង 180 ថ្ងៃ គិតចាប់ពីពេលដែលអំពើរើសអើងបានកើតឡើង ។

បើអ្នកមានចម្ងល់អំពីរបៀបដាក់ពាក្យប្តឹង អ្នកអាចទាក់ទងទៅកាន់ការិយាល័យ FTA ផ្នែកសិទ្ធិពលរដ្ឋ តាមលេខ 1-888-446-4511 ឬតាមអាសយដ្ឋានអ៊ីម៉េល FTA.ADAAssistance@dot.gov(តំណភ្ជាប់ផ្ញើអ៊ីម៉េល)

## លិខិតគំរូសម្រាប់ស្នើសុំការសម្រួលសមហេតុផល

[កាលបរិច្ឆេទ]

ជូនចំពោះ [ក្រុមហ៊ុនដឹកជញ្ជូនសាធារណៈ] ៖

ខ្ញុំបាទ/នាងខ្ញុំ សរសេរលិខិតនេះ ដើម្បីស្នើសុំការសម្រួលសមហេតុផល ដែលបណ្តាលពីពិការភាពនៅក្នុងខ្លួនរបស់ខ្ញុំបាទ/នាងខ្ញុំ ។

ខ្ញុំបាទ/នាងខ្ញុំ [ជា/នឹងក្លាយជា] អតិថិជនរបស់ [ក្រុមហ៊ុនដឹកជញ្ជូន] ។  ដោយសារតែបញ្ហាពិការភាពក្នុងខ្លួនខ្ញុំបាទ/នាងខ្ញុំ ធ្វើឲ្យខ្ញុំបាទ/នាងខ្ញុំ ត្រូវការភាពសម្រួលមួយចំនួនដូចខាងក្រោម ៖ [រាយមុខសំណើសុំការសម្រួល] ។

[គ្រូពេទ្យ/ពេទ្យវិកលចរិក/ពេទ្យចិត្តសាស្រ្ត/ពេទ្យព្យាបាល/បុគ្គលិកសង្គមកិច្ច/អ្នកព្យាបាលអាជីព/បុគ្គលផ្សេងទៀត (សូមរៀបរាប់)] របស់ខ្ញុំបាទ/នាងខ្ញុំ យល់ឃើញថា ការកែសម្រួលទាំងអស់នេះគឺមានភាពចាំបាច់ចំពោះពិការភាពរបស់ខ្ញុំបាទ/នាងខ្ញុំ ។  សូមមេត្តាពិនិត្យមើលលិខិតភ្ជាប់របស់ [ឈ្មោះគ្រូពេទ្យ ឬអ្នកឯកទេស] ។

ច្បាប់សហព័ន្ធ និង ច្បាប់រដ្ឋ តម្រូវឲ្យក្រុមហ៊ុនផ្តល់សេវាកម្ម ធ្វើការសម្រួលសមរម្យចំពោះសិស្ស និងអ្នកដាក់ពាក្យដែលមានពិការភាពជាប់ខ្លួន ។ សូមឆ្លើយតបចំពោះការស្នើសុំនេះឲ្យបានត្រឹមថ្ងៃទី [កាលបរិច្ឆេទ] ។ សូមកុំស្ទាក់ស្ទើរក្នុងការទាក់ទងមកកាន់ខ្ញុំបាទ/នាងខ្ញុំ តាម [លេខទូរស័ព្ទ និង/ឬអាសយដ្ឋានអ៊ីម៉េលរបស់អ្នក] បើលោកអ្នកមានសំណួរអ្វីមួយ ។

សូមអរគុណ ។ ដោយក្តីគោរពដ៏ស្មោះអំពីខ្ញុំបាទ/នាងខ្ញុំ

[ឈ្មោះរបស់អ្នក]

[អាសយដ្ឋានរបស់អ្នក]

# លិខិតគាំទ្រគំរូ

[កាលបរិច្ឆេទ]

ជូនចំពោះ [ក្រុមហ៊ុនដឹកជញ្ជូនសាធារណៈ]៖

ខ្ញុំបាទ/នាងខ្ញុំជា [គ្រូពេទ្យ/ពេទ្យវិកលចរិក/ពេទ្យចិត្តសាស្ត្រ/ពេទ្យព្យាបាល/បុគ្គលិកសង្គមកិច្ច/អ្នកព្យាបាលអាជីព] របស់ [ឈ្មោះ] ហើយខ្ញុំបាទ/នាងខ្ញុំបានដឹងពីស្ថានភាពពិការភាពរបស់គាត់ ។ [រូបគាត់] មានពិការភាពដែលបណ្តាលឲ្យការបំពេញមុខងាររបស់រាងកាយមានដែនកំណត់ ។ ដែនកំណត់នេះមានរួមបញ្ចូលនូវ [រាយមុខដែនកំណត់មុខងាររាងកាយដែលតម្រូវឲ្យមានការស្នើសុំការកែសម្រួល] ។

[ការសម្រួលដែលបានស្នើសុំ] មានសារៈសំខាន់ចំពោះ [ឈ្មោះ] ដើម្បីប្រើប្រាស់ [ឈ្មោះមធ្យោបាយធ្វើដំណើរសាធារណៈ] ។ [រៀបរាប់ពីផលប្រយោជន៍នៃការកែសម្រួល ដែលអាចជួយ ឬគាំទ្រដល់អ្នកស្នើសុំ] ។

សូមថ្លែងអំណរគុណចំពោះការផ្តល់ការកែសម្រួលសម្រាប់ [ឈ្មោះ] ។

ដោយក្តីគោរពដ៏ស្មោះអំពីខ្ញុំបាទ/នាងខ្ញុំ

[ឈ្មោះ និងមុខតំណែង]